ក្រុមហ៊ុនហ្គ្រេន ធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី

**GRAND TWINS INTERNATIONAL (CAMBODIA) PLC.**

PHUM TRA PANG POR, SANGKAT CHOM CHAU, KHAN POSENCHEY, PHNOM PENH CITY, CAMBODIA

TEL: 855-23-890 325 FAX: 855-23-890 326, E-mail: gmic.sr02@gmico.com

# សេចក្ដីជូនដំណឹង

ចាប់ពីម៉ោង ១២:០៥ នាទី រហូតដល់ម៉ោង ១៤:០៥ នាទី នាថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៤ មានព្រឹត្តិការណ៍នៃការតវ៉ាមួយកើតឡើងនៅមុខក្រុមហ៊ុន ហ្គ្រេន ធ្វីន ដោយកើតឡើងពីការញុះញុងពីសហព័ន្ធសហជីពដែលជាសហជីពមកពីខាងក្រៅក្រុមហ៊ុន ប៉ុន្តែការតវ៉ានេះមិនមានការយល់ព្រម និងចូលរួមពី សហជីពកម្មករកាត់ដេរ ហ្គ្រេនធ្វីន និងសហព័ន្ធសហជីពអភិវឌ្ឍកម្មករកាត់ដេរកម្ពុជា ដែលមានភាព ជាតំណាងកម្មកររបស់ក្រុមហ៊ុននោះទេ ហើយតាមច្បាប់ការតវ៉ារបៀបនេះ ត្រូវមានការជូនដំណឹងជាមុនដល់ក្រុមហ៊ុននិងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ការតវ៉ានេះបានធ្វើឱ្យកម្មករ-កម្មការនីរបស់ក្រុមហ៊ុនហ្គ្រេនធ្វីន មិនអាចចូលបម្រើការងារក្នុងក្រុមហ៊ុន ដែលហេតុការណ៍នេះបណ្ដាលឱ្យប៉ះពាល់ជាយថាហេតុដល់ខ្សែសង្វាក់ផលិតកម្មរបស់ក្រុមហ៊ុន។ ហើយការញុះញុងពីខាងក្រៅដើម្បីទប់ស្កាត់កម្មករមិនឱ្យធ្វើការបានជាប្រក្រតីនេះ គឺនៅមានបន្តមកដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៤ នេះ។ដើម្បីទប់ស្កាត់នូវបញ្ហាខាងលើ ថ្នាក់គ្រប់គ្រងក្រុមហ៊ុនហ្គ្រេនធ្វីន បានចាត់វិធានការតាម ផ្លូវច្បាប់ដោយដាក់ពាក្យសុំអន្តរាគមន៍ទៅអាជ្ញាធរនិងស្ថាប័នមានសមត្ថកិច្ចមួយចំនួនដូចជាលោកប្រធានសមាគមរោងចក្រ កាត់ដេរនៅកម្ពុជាអាជ្ញាធរមូលដ្ឋាន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងឯកឧត្តមនាយកខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ក្រៅពីវិធានការតាម ផ្លូវច្បាប់ ក្រុមហ៊ុន ហ្គ្រេន ធ្វីន កំពុងបន្តរិះរកវិធីសាស្ត្រក្នុងការដោះស្រាយគ្រប់មធ្យោបាយផ្សេងទៀតដោយសន្តិវិធីក្នុងការសម្របសម្រួលដើម្បីអនុញ្ញាតឱ្យរោងចក្រអាចចាប់ផ្ដើមដំណើរការផលិតកម្ម ជាប្រក្រតី វិញក្នុងពេលឆាប់ៗខាងមុខនេះ។

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន ហ្គ្រេន ធ្វីន
GRAND TWINS INTERNATIONAL (CAMBODIA) PLC.
KINGDOM OF CAMBODIA

ភ្នំពេញ ថ្ងៃ ទី ២២ ខែ តុលា ឆ្នាំ ២០១៤